## ទំព័រវ៉ិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា មានមោទនភាពក្នុងការផ្ដល់ជូននូវឧបករណ៍ដែល ឪពុកម្ដាយ និង សមាជិកគ្រួសារ អាចប្រើដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ កូន និង សាលារៀន របស់ពួកគាត់។ ទំព័រវ៉ិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ផ្ដល់ជូនលោកអ្នកនូវវិធីទទួល ព័ត៌មានដែលមានតម្លៃ អំពី ការអប់រំ និង សាលារៀន របស់កូនលោកអ្នក។ តាមរយៈទំព័រវ៉ិបសែនេះ លោកអ្នកអាចមើល ប្រវត្តិនៃការសិក្សា លទ្ធផលនៃការ ប្រឡង វត្តមានអវត្តមាន របស់កូនលោកអ្នក និង អ្វីៗជាច្រើនទៀត។ លោកអ្នកក៏អាចស្នើសុំឲ្យគេផ្ញើ សារតាមទូរស័ព្ទដៃ អ៊ីម៉ែល និង/ឬ ទូរស័ព្ទទាក់ទង អំពី បញ្ហាសំខាន់ៗ ដែលអាចប៉ះពាល់ដល់កូនរបស់លោកអ្នក (ឧ. ការបិទសាលា ដែលទាក់ទងនឹងអាកាសធាតុមិនល្អ ការរំឭកអំពីអវត្តមាន និង កម្មវិធីដែលនឹង កើតមានឡើង ដែលក្រុមគ្រួសារមានចំណាប់អារម្មណ៍។)

លោកអ្នកអាចចូលមើលបានគ្រប់ពេលវេលាតាមរយៈ កុំព្យូទ័រ កុំព្យូទ័របន្ទះ (tablet) ឬ ទូរស័ព្ទដៃ!

## តើខ្ញុំត្រូវចុះឈ្មោះសម្រាប់ ទំព័រវ៉ិបសែថ្មីសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ និង បង្កើតគណនីរបស់ខ្ញុំ ដោយវិធីណា?

លោកអ្នកត្រូវមានអ៊ីម៉ែលផ្ទាល់ខ្លួន ដើម្បីបង្កើតគណនីទំព័រវ៉ិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ។ លោកអ្នកអាចបង្កើតគណនីអ៊ីម៉ែលដោយឥតគិតថ្លៃ ដោយប្រើ ជីមែល (Gmail) អោតលុក (Outlook) យ៉ាហូ (Yahoo) ឬ ជាមួយសេវាកម្មស្រដៀងគ្នានេះ។

## តើខ្ញុំត្រូវចាប់ផ្ដើមពីកន្លែងណា?

គ្រាន់តែចូលទៅ http://signup.philasd.org នៅក្នុងកម្មវិធីវ៉ិបសែដែលលោកអ្នកប្រើ ហើយត្រូវមាន លេខសម្ងាត់សម្រាប់បញ្ជាក់ របស់លោកអ្នក។

## តើអ្វីទៅជា លេខសម្ងាត់សម្រាប់បញ្ជាក់ (Confirmation Code)?

ឪពុកម្ដាយ ឬ អាណាព្យាបាល ប្រើលេខសម្ងាត់សម្រាប់បញ្ជាក់ ដើម្បីចុះឈ្មោះ។ គេត្រូវការ លេខសម្ងាត់សម្រាប់បញ្ជាក់ តែម្ដងប៉ុណ្ណោះ ហើយវានឹងអស់សុ ពលភាពនៅថ្ងៃទីមួយជារៀងរាល់ខែ។ លោកអ្នកអាចសុំ លេខសម្ងាត់សម្រាប់បញ្ជាក់ របស់លោកអ្នកពីសាលារៀនរបស់កូនលោកអ្នក ឬ លោកអ្នកអាចចុះ ឈ្មោះតាមអ៊ីនធ័រណិតតែម្ដង!

## បើសិនជាលោកអ្នកមាន លេខសម្ងាត់សម្រាប់បញ្ជាក់ របស់លោកអ្នក៖

១.) ចុចលើ ***Yes, take me to Account Registration*** ***(បាទ/ចាស នាំខ្ញុំទៅបង្កើតគណនី)***។
២.) បញ្ចូលនាមត្រកូលរបស់លោកអ្នក និង លេខសម្ងាត់សម្រាប់បញ្ជាក់។ ចុច ***Next*** ***(បន្ទាប់)***។
៣.) បញ្ចូល អ៊ីម៉ែល របស់លោកអ្នក។
៤.) បញ្ជាក់ពីគណនីអ៊ីម៉ែលរបស់លោកអ្នក ដោយចុចលើបណ្ដាញតភ្ជាប់ ដែលគេបានផ្ដល់ជូននៅក្នុងសារអ៊ីម៉ែល។ ចុចលើបណ្ដាញតភ្ជាប់វ៉ិបសែ នៅ ក្នុងអ៊ីម៉ែល ដើម្បីបំពេញការចុះឈ្មោះរបស់លោកអ្នក។
៥.) បន្ទាប់ពីលោកអ្នកបានចុះឈ្មោះរួចហើយ លោកអ្នកនឹងរៀបចំ «ការរៀបចំសុវត្ថិភាព (Security Settings)» របស់លោកអ្នក។ ជ្រើសរើសពាក្យសម្ងាត់ និង ផ្ដល់ចម្លើយទៅនឹងសំណួរសុវត្ថិភាពចំនួនបី។
៦.) ចូលទៅកាន់គណនីថ្មីរបស់លោកអ្នក ដោយប្រើ អ៊ីមែល និង ពាក្យសម្ងាត់ថ្មី របស់លោកអ្នក។

## បើសិនជាលោកអ្នកគ្មាន លេខសម្ងាត់សម្រាប់បញ្ជាក់ របស់លោកអ្នកទេ៖

១.) សូមចុចលើ ***No, I would like to look up my Confirmation Code*** ***(ទេ ខ្ញុំចង់រកមើល លេខសម្ងាត់សម្រាប់បញ្ជាក់របស់ខ្ញុំ)***។
២.) បញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់កូនលោកអ្នក (បើសិនជាលោកអ្នកមានកូនលើសពីម្នាក់ លោកអ្នកត្រូវការបញ្ចូលព័ត៌មានរបស់កូនតែម្នាក់ប៉ុណ្ណោះ។)
៣.) ជ្រើសរើស ឈ្មោះ និង លេខទូរស័ព្ទបច្ចុប្បន្ន របស់លោកអ្នក ពីឯកសាររបស់សិស្ស ដើម្បីស្នើសុំលេខសម្ងាត់សម្រាប់បញ្ជាក់។ គេអាចផ្ញើ លេខ សម្ងាត់សម្រាប់បញ្ជាក់ តាមសារសម្លេង ឬ តាមសារទូរស័ព្ទដៃ។
៤.) ឥឡូវនេះលោកអ្នកមានលេខសម្ងាត់សម្រាប់បញ្ជាក់របស់លោកអ្នកហើយ ចុចបណ្ដាញតភ្ជាប់ដើម្បីត្រឡប់ទៅការបង្កើតគណនីវិញ ហើយចាប់ផ្ដើម បំពេញ។